ផ្ទះយុវជនដើម្បីមិត្តភាពកម្ពុជា-ចិន
東中友好青年之家

# សេចក្តីប្រកាសព័ត៌មាន
## ស្តីពី
## លទ្ធផលនៃវេទិកាផ្លាស់ប្តូរមិត្តភាពកម្ពុជា-ចិន "ផ្លូវសូត្រផ្សារភ្ជាប់ប្រជាជននិងប្រជាជន" ឆ្នាំ២០២៥

ផ្ទះយុវជនដើម្បីមិត្តភាពកម្ពុជា-ចិន សហការជាមួយមូលនិធិចិនដើម្បីសន្តិភាព និងការអភិវឌ្ឍ (CFPD) ក្រោមការគាំទ្រពីស្ថានទូតចិនប្រចាំនៅកម្ពុជា និងរាជរដ្ឋាភិបាលកម្ពុជារួមទាំងដៃគូសហការមកពីស្ថាប័នរដ្ឋ និងឯកជនបានរៀបចំ **វេទិកាផ្លាស់ប្តូរមិត្តភាពកម្ពុជា-ចិន "ផ្លូវសូត្រផ្សារភ្ជាប់ប្រជាជននិងប្រជាជន" ឆ្នាំ២០២៥** ក្រោមមូលបទ "**មិត្តភាពដ៏រឹងមាំគ្រប់រដូវកាល ផ្សារភ្ជាប់បេះដូងប្រជាជន និងប្រជាជន**" កាលពីថ្ងៃទី១៤-១៦ ខែធ្នូ ឆ្នាំ២០២៥ នៅសណ្ឋាគារហៃយ៉ាត់រីជេនស៊ីភ្នំពេញ។

ពិធីបើកជាផ្លូវការបានប្រព្រឹត្តទៅក្រោមអធិបតីភាព **ឯកឧត្តម ហ៊ុន ម៉ានី** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ តំណាងដ៏ខ្ពង់ខ្ពស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** និង **ឯកឧត្តម វ៉ាង វិនពីន** ឯកអគ្គរដ្ឋទូតសាធារណរដ្ឋប្រជាមានិតចិនប្រចាំកម្ពុជា ព្រមទាំងមានការចូលរួមពីថ្នាក់ដឹកនាំ ស្ថាប័នរដ្ឋនិងឯកជន សាកលវិទ្យាល័យ ស្ថាប័នស្រាវជ្រាវ អង្គការ សមាគម ប្រព័ន្ធផ្សព្វផ្សាយ សហគ្រិនសិល្បៈករ យុវជន មកពីចិន និងកម្ពុជា សរុបប្រមាណ៣០០នាក់។

នៅក្នុងសុន្ទរកថាបើក **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** រំលឹកពីទំនាក់ទំនងយ៉ាងជិតស្និទ្ធរវាងប្រទេសទាំងពីរ ហើយបានរំលេចពីសមិទ្ធិផលនៃទំនាក់ទំនងការទូតនៃប្រទេសទាំងពីរគួរកត់សម្គាល់សម្រាប់ឆ្នាំ២០២៥នេះរួមមាន ព្រះរាជដំណើរទស្សនកិច្ចរបស់ **ព្រះករុណាព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា** ទៅប្រទេសចិន ដំណើរទស្សនកិច្ចផ្លូវរដ្ឋរបស់ **ឯកឧត្តមប្រធានាធិបតី ស៊ី ជីនពីង** កាលពីខែមេសា វត្តមានរបស់**សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី** នៅក្នុងកិច្ចប្រជុំកំពូលអង្គការសហប្រតិបត្តិការសៀងហៃបូកជាដើម ដែលសុទ្ធតែបានជំរុញនូវក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការដែលមានស្រាប់ និងពង្រឹងបន្ថែមទៀតនូវមិត្តភាពដែកថែប។ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី**បានគូសបញ្ជាក់ថា វេទិកាផ្លាស់ប្តូរមិត្តភាពកម្ពុជា-ចិននេះពិតជាមានសារៈសំខាន់ក្នុងបរិការណ៍តំបន់ និងសកលដែលមានភាពមិនប្រាកដប្រជា ដែលជួយដល់ការផ្សារភ្ជាប់ទំនាក់ទំនង និងសាមគ្គីភាពជាប្រពៃណីរវាងកម្ពុជា និងចិនកាន់តែស្អិតរមួត និងប្រកបដោយភាពសុខដុម ជាពិសេស ការផ្សារភ្ជាប់បេះដូងរវាងប្រជាជននិងប្រជាជន ដែលជាគ្រឹះដ៏រឹងមាំនៃចំណងមិត្តភាពដែកថែប។ ប្រទេសទាំងពីបានបានឯកភាពគ្នាជំរុញបន្ថែមទៀតនូវសន្ទុះការកសាងសហគមន៍ជោគវាសនារួមកម្ពុជា-ចិនគ្រប់រដូវកាលក្នុងយុគសម័យថ្មី ប្រកបដោយ គុណភាពខ្ពស់ កម្រិតខ្ពស់ និងស្តង់ដារខ្ពស់។

ថ្លែងទៅកាន់ពិធីបើកនេះផងដែរ **ឯកឧត្តម វ៉ាង វិនពីន** បានកោតសរសើរការរៀបចំវេទិកាដ៏មានសារៈសំខាន់នេះហើយបានវាយតម្លៃខ្ពស់ការរៀបចំមហោស្រពមិត្តភាពកម្ពុជាចិនកាលពីឆ្នាំមុននៅក្រុងសៀមរាប។ ឯកឧត្តមក៏បានគូសបញ្ជាក់ថា ប្រទេសចិនគាំទ្រនិងត្រៀមខ្លួនក្នុងការជំរុញនៅកិច្ចសហប្រតិបត្តិការដែលមានស្រាប់ឱ្យកាន់តែរឹងមាំដូចជាកិច្ចសហប្រតិបត្តិការត្បូងពេជ្រ ពាណិជ្ជកម្មសេរី ផែនការសកម្មភាពកសាងសហគមន៍ជោគវាសនារួមក្នុងយុគសម័យថ្មីជាដើម ដើម្បីសម្រេចបានលទ្ធផលជាក់ស្តែងបន្ថែមទៀត។ ឯកឧត្តមបានបញ្ជាក់ពីការចូលរួមបន្តគាំទ្រសហការរាល់គំនិតផ្តួចផ្តើមសហប្រតិបត្តិការរបស់ផ្ទះយុវជនដើម្បីមិត្តភាពកម្ពុជាចិន និងមូលនិធិចិនដើម្បីសន្តិភាពនិងការអភិវឌ្ឍ។

អាសយដ្ឋាន៖ ជាន់ទី១៦ អគារមជ្ឈមណ្ឌលអភិវឌ្ឍធុរកិច្ច មហាវិថីអូស៊ីអាយស៊ី ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ | Tel: +855 17 392 333 | Email: info@youthhouse-ccf.org
Address: 16th floor of Business Development Center, OCIC Blvd, Khan Chroy Changvar, Phnom Penh | Website: www.youthhouse-ccf.org

ក្នុងវេទិកានេះ ក៏បានរៀបចំកិច្ចពិភាក្សាដំណាលគ្នាចំនួនពីរសម្រាប់ការផ្លាស់ប្តូរទស្សនៈទៅវិញទៅមករវាងវាគ្មិនមកពីប្រទេសទាំងពីរ ក្នុងការជំរុញកិច្ចសហប្រតិបត្តិការក្នុងវិស័យអប់រំកម្រិតឧត្តមសិក្សា និងការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ សង្គមស៊ីវិល ការធ្វើឱ្យស៊ីជម្រៅកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច ពាណិជ្ជកម្ម និងវិនិយោគបន្ថែមទៀត ដើម្បីគាំទ្រដល់ការអភិវឌ្ឍ និងវិបុលភាពរួមរយៈពេលវែង។

បន្ថែមពីនេះ យើងបានរៀបចំឱ្យស្ថាប័ន និងសហគ្រាសមកពីប្រទេសទាំងពីរបង្ហាញនូវសក្តានុពល និងការបង្កើតទំនាក់ទំនងដើម្បីឈានទៅការបង្កើតឱកាសកិច្ចសហប្រតិបត្តិការរវាងគ្នា។ ក្នុងនោះ មានក្រុមហ៊ុននិងស្ថាប័នកម្ពុជានិងចិនចំនួនលើសពី២០ បានឡើងធ្វើបទបង្ហាញពីសក្តានុពល និងទិសដៅនៃការបង្កើតភាពជាដៃគូរវាងគ្នា។ ជាលទ្ធផលមានស្ថាប័នចំនួនយ៉ាងហោច១០ បានចុះហត្ថលេខាលើការព្រមព្រៀង ដើម្បីបង្កើតកិច្ចសហប្រតិបត្តិការ និង ការប្រកាសនូវគម្រោងនិងជំនួយសម្រាប់សកម្មភាពសង្គមផ្សេងៗ។

ថ្លែងក្នុងកិច្ចប្រជុំបូកសរុប **ឯកឧត្តម សុខ ពិសិដ្ឋ** អគ្គលេខាធិការផ្ទះយុវជន បានបញ្ជាក់ថាវេទិកាឆ្នាំនេះទទួលបានលទ្ធផលផ្លែផ្កាជាច្រើន បានរឹតចំណងមិត្តភាពប្រជាជននៃប្រទេសទាំងពីរ តភ្ជាប់កិច្ចសហប្រតិបត្តិការអប់រំ ធុរកិច្ចយុវជន និងការផ្លាស់ប្តូរវប្បធម៌នៃប្រទេសទាំងពីរ។

**ឯកឧត្តម សុខ សូកេន** រដ្ឋមន្ត្រីក្រសួងអធិការកិច្ច និងជាអនុប្រធានក្រុមប្រឹក្សាភិបាលផ្ទះយុវជនបានថ្លែងក្នុងពិធីលៀងសាយភោជន៍ថា វេទិកាផ្លាស់ប្តូរមិត្តភាពកម្ពុជា-ចិនឆ្នាំ២០២៥ គឺជាចលករដ៏សំខាន់ ដែលបានរួមចំណែកលើកកម្ពស់ទំនាក់ទំនងប្រជាជននិងប្រជាជន ជាពិសេសការផ្លាស់ប្តូររវាងយុវជននិងយុវជន វប្បធម៌ និងប្រពៃណីដ៏ផូរផង់នៃប្រទេសកម្ពុជា-ចិន ព្រមទាំងការកសាងចំណងមិត្តភាព ទំនុកចិត្ត និងការយល់គ្នាទៅវិញទៅមក ដើម្បីស្វែងរកនូវឱកាសវិនិយោគ និងធុរកិច្ចរវាងសហគ្រិនវ័យក្មេងនៃប្រទេសទាំងពីរ។

គណៈប្រតិភូសហគ្រិនមកពីចិននិងកម្ពុជា ក៏បានចូលជួបសម្តែងការគួរសមជាមួយ **លោកជំទាវ ចម និម្មល** រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ក្នុងគោលបំណងបង្ហាញពីផែនការក្នុងការមកវិនិយោគ ជំរុញពាណិជ្ជកម្មទៅមក និងទទួលការណែនាំបន្ថែមសម្រាប់ទំនាក់ទំនងសេដ្ឋកិច្ចរវាងប្រទេសទាំងពីរ។

ថ្ងៃពុធ ១២រោច ខែមិគសិរ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០២៥

**អគ្គលេខាធិការដ្ឋាន**